

# កំណើត នៃសាធារណរដ្ឋមួយ

សេរីការ : មហាវិថីគ្មានទ្វារ វាបើកច្រកឱ្យអស់ផ្លូវតូចៗចូលបាន

អត្ថបទនេះ ធ្លាប់ចុះផ្សាយក្នុងព្រឹត្តិប័ត្រ « មូលខ្មែរ » លេខ ១៣៣ ខែតុលា ១៩៩២។

ឧប្បត្តិហេតុដ៏អស្ចារ្យ បានចាប់កំណើតនៅប្រទេសកម្ពុជា នាថ្ងៃទី១០ តុលា ១៩៧០ ប្រៀបបានទៅនឹង គ្រាប់រំសេវផ្ទុះ។ សាធារណរដ្ឋខ្មែរ បានផុសចេញផ្លោរឡើង នៅកណ្តាលរាជាណាចក្រមួយ ដែលមាន រចនាសម្ពន្ធគ្រប់គ្រងរដ្ឋ តាំងពីរាប់សតវត្សមកហើយ ពុំអាចនឹងធ្វើអោយសាធារណរដ្ឋមួយ អាចចាប់កំណើតដោយចៃដន្យបានឡើយ។

ទុតព្រះទ័យ និង អំណាចផ្ទាល់ព្រះអង្គដ៏មហិមា ចងគំនុំ និង មហាប្រទេស សហរដ្ឋអាមេរិក ហើយជាពិសេស ទុតព្រះទ័យទាំងស្រុង ទៅលើមហាមិត្តចិន និង វៀតណាមកុម្មុយនិស្ត សម្តេចសីហនុ បានភ្លាត់ស្នៀតយ៉ាងធ្ងន់ នៅថ្ងៃទី១៨ មីនា ១៩៧០ ដោយទុកឱកាសអោយរាស្រ្តខ្មែរទម្លាក់ ដកងារពីប្រមុខរដ្ឋ ហើយដករាជបល្ល័ង្ក ចេញពីជម្ពូទុញ្ញខ្មែរ នៅថ្ងៃទី១០ តុលា ឆ្នាំដដែលនេះបាន។

ថ្វីត្បិតតែ ឱកាសប្រវត្តិសាស្រ្តទាំងពីរនេះ បានផ្តល់លក្ខន្តិកៈ ខ្មែរ អោយទៅជាសាធារណរដ្ឋ ប្រកបដោយវរជន ដូចជា លោក លន់ នល់ ទ្រង់ ស៊ីសុវត្ថ សិរិមតៈ លោក ចេង ហេង លោក អ៊ិន

## កំណើត នៃសាធារណរដ្ឋមួយ

គាំ ប្រទេសខ្មែរ នៅរក្សារចនាសម្ព័ន្ធ និង ឧត្តមគតិ រាជានិយម នៅឡើយ។ ស្ថានភាពប្រទេសខ្មែរ នៅពេលនោះពុំអាចឧបត្ថម្ភ អ្វីដល់កំណើត នៃឧត្តមគតិ « ជនសាធារណរដ្ឋ » អ្វីបន្តិចទេ ដោយ :

១. ពួកកុម្មុយនិស្ត ទាំងមហាអំណាច ទាំងកូនជីង យកខ្មែរធ្វើជាទីលាន បង្ហាញកំលាំងបាយទៅពួកលោកសេរី។

២. ទម្ងន់ស្ថានការណ៍ ប្រវត្តិសាស្ត្រមួយទៀត : សម្តេចសីហនុ ជាអតិតស្តេចសោយរាជ្យទី១ ដែលហ៊ានប្រកូកហៅរាស្ត្រខ្មែរ អោយក្រោក ធ្វើសង្គ្រាម ប្រឆាំងនឹងសង្គមខ្មែរគ្នាឯង ដោយពុំបានប៉ាន់ នូវតម្លៃ នៃសង្គ្រាមក្នុងស្រុក។

៣. វរជន ដឹកនាំសង្គ្រាម ក្នុងសាធារណរដ្ឋ មិនបានដឹកសង្គ្រាមខ្មែរ ក្នុងនាមសម្ព័នមិត្តលោកសេរី ក៏ប៉ុន្តែជាអ្នកបំរើនយោបាយ សហរដ្ឋអាមេរិក សុទ្ធសាធ។

ហេតុនេះហើយ ការប្រទ្បបល់ ក្នុងសតិបញ្ញា ពុំអាចដក « ទម្លាប់រាជានិយម » អោយផុតពីខួរក្បាលខ្មែរគ្រប់គ្នាបាន ទសងនេះ ដោយពុំអាច រាប់ទាំង ការឃោសនា ភូតភរ របស់ពួកកុម្មុយនិស្ត មករំលាយសង្គមខ្មែរផង។ ស្សេរភាព របស់រាជានិយម ចំនួនរាប់សតវត្ស បើប្រៀបធៀបទៅនឹង អស្តិសុខ កើតនៅសម័យ យុវសាធារណរដ្ឋ ធ្វើអោយខ្មែរយើង មានការបារម្ភច្រើន។ « ស្សេរភាព ជាការធានាជីវិត បើគេចេះសម្របសម្រួល ទៅតាមកំលាំងព្យុះ នៃអំណាច » មនុស្ស នោះក្លាយទៅ

## កំណើត នៃសាធារណរដ្ឋមួយ

ជា ទាសករ របស់សង្គមក៏ដោយ អោយតែបានរស់។ ក៏ប៉ុន្តែសេរីភាព របស់មនុស្សនៅក្នុងសង្គម ជាសុភមង្គលមួយដែរ នៅពេលដែរបាន ក្រេបរស់ជាតិម្តង ហើយមនុស្ស ក្លាយទៅជាបុគ្គលសក្ការៈ ហើយពុំអាចក្លាយទៅជា ទាសករវិញឡើយ។ សាធារណរដ្ឋ ពិតប្រាកដគឺសង្គម ដែលពោរពេញទៅដោយបុគ្គលសក្ការៈ ដែលមានជំនឿទៅលើ គុណធម៌ ស្គាល់ និងបំបាត់បាបកម្ម មានចិត្តសាធាជ្រះថ្លា ហ៊ានចែកចាយ នូវសុភមង្គល របស់ខ្លួន ដល់សាធារណជនឯទៀតៗ ដោយក្លាហាន។ ឧត្តមគតិ សាធារណរដ្ឋ ជាជីវិតរស់រវើក មានកំណើត ហើយមានព្រលឹងធាត់ធំ មានការឈឺចាប់ឬឈឺថ្កាត់ដូចមនុស្សដែរ។

សាធារណរដ្ឋខ្មែរ មានកំណើតឡើង នៅថ្ងៃទី១០ តុលា ១៩៧០ ក្នុងបរិយាកាស អាប់អួរជាទីបំផុត។ ខំចម្លងក្បួនពីប្រទេសលោកសេរី ខំអោយ ប្រទេសជាមិត្តជាច្រើន ជួយជម្រុញអោយសាធារណរដ្ឋ លូតលាស់ ក្នុងមហាសង្គ្រាម មនោគមន៍វិជ្ជា។ មនុស្សជាច្រើន បានបូជាជីវិតក្នុងសង្គ្រាម ដើម្បីកំណើតសាធារណរដ្ឋ បន្លឺស្រាងៗ បានលេចចេញអំពី ការបូជាជីវិតនេះ គឺកំណើត នៃការស្រឡាញ់សេរីបុគ្គល ការស្រឡាញ់ឯករាជ្យ របស់

ជាតិខ្មែរ។ ក្នុងមួយជីវិតរដ្ឋខ្មែរ ដែលរស់ ក្នុងលក្ខន្តិកៈ « សាធារណរដ្ឋសេរី » ស្ថានភាពប្រចក្ខ បិយុគ បញ្ជាក់អោយឃើញច្បាស់ អំពី ចលនាសាធារណរដ្ឋនិយម :

## កំណើត នៃសាធារណរដ្ឋមួយ

យុគទី១ : នៅដំបូងឆ្នាំ ១៩៧០ នៅពេលដែល យួន-ចិន កុម្មុយនិស្ត ខ្មែរក្រហម សម្តេចសីហនុ សម្រេចចិត្ត វាយសាធារណរដ្ឋខ្មែរ គេអាចសង្កេតឃើញ ការសម្រេចចិត្ត ប្តូរម្តេច ការពារប្រទេស យ៉ាងគគ្រឹកគគ្រេង របស់ពលរដ្ឋខ្មែរ ទោះបីដឹងថាមាន មធ្យោបាយតិចក៏ដោយ។ យើងអាចសន្ទត់ថា យុគនេះជាយុគ « ចលនា សាធារណរដ្ឋ »។

យុគទី២ : នៅឆ្នាំ ១៩៧២-៧៣ ចម្បាំងរាំងជល់ បាននាំអោយប្រទេសខ្មែរ ក្លាយទៅជា « សាធារណរដ្ឋ យោធានិយម » ពេលនោះ ប្រជាជនខ្មែរ មានទាំង យុវជន និស្សិត ក្រោកឡើងប្រឆាំងនឹងការរីកចំរើន នៃអំណាចយោធា ហួសកំណត់អំណាច សាធារណរដ្ឋ។ ចលនានោះឈ្មោះ « ចលនា វិមានឯករាជ្យ » បានប្រមូល ប្រជាជន និង យុវជន រាប់ម៉ឺននាក់ អោយដាស់ប្រទេស អោយគេចចេញអំពី ផ្លូវផ្តាច់ការ យោធានិយម។ ចលនានោះ រលត់បាត់ទៅវិញ ក្រោមការគៀបសង្កត់ នៃអំណាចសាធារណរដ្ឋ ក៏ប៉ុន្តែបានប្តូររូបភាព និង ស្ថានភាពនយោបាយ សាធារណរដ្ឋខ្មែរ អស់រលីង លែងដូចដើមទៀត។

យុគទី៣ : នៅពេល សហរដ្ឋអាមេរិក សម្រេចចិត្ត ដកថយពីស្រុកខ្មែរ ទុកអោយ សាធារណរដ្ឋ យោធានិយម រលំក្រោមអាវុធ កុម្មុយនិស្ត និង សីហនុ នៅឆ្នាំ ១៩៧៣។ អ្នកសង្កេតការណ៍បរទេសទសងអស់ ចោទសួរថា ហេតុអ្វី ក៏បីប្អូនខែមក ហើយ សាធារណរដ្ឋ នៅមិនរលំ ? ពីព្រោះ បិដ្ឋសចុងក្រោយនេះ

## កំណើត នៃសាធារណរដ្ឋមួយ

បានបណ្ដុះផ្កាល សេរីភាពច្រើនណាស់ ហើយ សាធារណជន លែងអាចផ្ញើរ វាសនាខ្លួន ទៅលើ ទ្រឹស្ដី កុម្មុយនិស្ដ បានទៀត ហើយ ហេតុនេះហើយ បានជាបីខែចុងក្រោយនេះ ជាដំណាង នៃការប្រយុទ្ធ « ឧត្ដមគតិ សាធារណរដ្ឋនិយម ដៃទទេ » តទល់ នឹង « ម៉ាស៊ិន សង្គ្រាម ចិន-យួន កុម្មុយនិស្ដ » រហូតដល់ អវសាន លក្ខន្តិក: សាធារណរដ្ឋខ្មែរ។ ឧត្ដមគតិ សាធារណរដ្ឋ និយម ដែលគេស្មានតែ ស្លាប់បាត់បង់ជីវិតទៅហើយនៅពេល នោះ នៅបន្ដ ជាអចិន្ត្រៃយ៍នៅក្នុងព្រលឹង អ្នករំដោះនៅទល់ ដែន និង ប្រជាជនខ្មែរឯទៀត ដែលភៀសខ្លួន ជាបណ្ដោះ អាសន្ន មករស់នៅបរទេស។ លោក លន់ នល់ និង ទ្រង់ ស៊ីសុវត្ថ សិរិមត: មានគុណសម្បត្តិមួយ ដែលគេមិនអាចប្រកែកបាន : ហ៊ានរំលំបាន នូវរបស់ដែលគេស្មានថា រំលំមិនកើត គឺ សីហនុ និង រាជបល្ល័ង្ក។ អំពើនេះ ជាលក្ខណ: សំខាន់មួយ ដែលធ្វើអោ យខ្មែរហ៊ានទុកចិត្តលើខ្លួនឯង ហើយ អាចអោយ សតិ សាធារណរដ្ឋនិយម រស់យូរអង្វែងបាន។

ថ្ងៃទី១០ តុលា ១៩៧០ ជាថ្ងៃដែលប្រទេសខ្មែរ បានប្រកាសជា ឧឡារិក ថាជា « រដ្ឋរបស់សាធារណ » ចលនា មូលខ្មែរ ដើម្បីសេរី ភាព ប្រកាសប្រារព្វ ពិធីនេះ ដូចដែលបានធ្វើរៀងរាល់ឆ្នាំមក ហើយ។